ការវាយតម្លៃ

ការយល់ដឹង មីណេសូតា ដែលបានកែប្រែ

អំណាន

កម្មវិធីបរិយាយកម្រិតលទ្ធផល

ខែមិថុនា ឆ្នាំ 2013

Minnesota Department of Education

មាតិកា

កម្មវិធីបរិយាយកម្រិតលទ្ធផលសម្រាប់ Reading MCA-III, MCA-Modified និង MTAS 2

ណែនាំឲ្យយល់ពីកម្មវិធីបរិយាយកម្រិតលទ្ធផល MCA-Modified នៃអំណាន 6

ថ្នាក់ទី 5 – កម្មវិធីបរិយាយកម្រិតលទ្ធផលដែលត្រូវបានកែតម្រូវ 7

ថ្នាក់ទី 6 – កម្មវិធីកម្រិតលទ្ធផលដែលបានកែប្រែ 16

ថ្នាក់ទី 7 – កម្មវិធីបង្ហាញពីកម្រិតលទ្ធផលដែលបានកែប្រែ 21

ថ្នាក់ទី 8 – កម្មវិធីបរិយាយអំពីកម្រិតលទ្ធផលដែលបានកែប្រែ 25

ថ្នាក់ទី 10 – កម្មវិធីបរិយាយកម្រិតលទ្ធផលដែលត្រូវបានកែប្រែ 29

កម្មវិធីបរិយាយកម្រិតលទ្ធផលសម្រាប់ Reading MCA-III, MCA-Modified និង MTAS

ទិដ្ឋភាពរួម

មីណេសូតា បានចេញផ្សាយ *បទដ្ឋានការសិក្សាមីណេសូតា K-12 ដែលត្រូវបានកែតម្រូវ—អក្សរសាស្ត្រអង់គ្លេស* នៅឆ្នាំ 2010 ។ ដើម្បីកំណែបទដ្ឋាននេះ មីណេសូតា បានបន្ថែមបទដ្ឋានស្នូលអក្សរសាស្ត្រអង់គ្លេសដែលបានយល់ព្រមទាំងអស់។ ការវាយតម្លៃប្រតិបត្តិការលើកដំបូងដោយពឹងផ្អែកលើផ្នែកលើណានៃបទដ្ឋានដែលកែប្រែត្រូវបានធ្វើនៅនិទាឃរដូវ ឆ្នាំ 2013។

បទដ្ឋានសិក្សា K-12 មីណេសូតាឆ្នាំ 2010 - អក្សរសាស្ត្រអង់គ្លេស តំណាងឲ្យការរំពឹងទុកដ៏សំខាន់ពីការយល់ ដឹងអំពីអំណានទូវអ្វីដែលត្រូវបានរំពឹងទុកក្នុងបទដ្ឋានសិក្សាឆ្នាំ 2003។ ការរំពឹងទុកទាំងនេះបានប្រតិបត្តិការនៅក្នុងព័ត៌មានលម្អិតអំពីការធ្វើតេស្ត និងការវាយតម្លៃតាមរយៈភាពស្មុគស្មាញដែលបានកើនឡើង និងភាពតឹងរ៉ឹងក្នុងអំណានអត្ថបទសម្រង់ និងចំណុចធ្វើតេស្ត។ គោលបំណងនៃបទដ្ឋាន និងការវាយតម្លៃដែលបានកែប្រែគឺដើម្បីធានាថាសិស្សបង្ហាញរួចជាស្រេចពីមហាវិទ្យាល័យ និងវិជ្ជាជីវៈ។

ការវាយតម្លៃលើអំណាន មីណេសូតា

កម្មវិធីបរិយាយអំពីកម្រិតលទ្ធផល (ALDs) ក្នុងឯកសារនេះត្រូវបានធ្វើជាណយលក្ខណ៍អក្សរសម្រាប់ការវាយតម្លៃលើអំណានចំនួនបីបានម៉ៀបចំជាផ្នែកមួយនៃប្រព័ន្ធវាយតម្លៃមីណេសូតា។ ព័ត៌មានលម្អិតអំពីការធ្វើតេស្ត និង ALDs សម្រាប់ការវាយតម្លៃលើអំណាន មីណេសូតាទាំងអស់ផ្អែកលើផ្នែកអំណានៃបទដ្ឋាន*សិក្សា K-12 មីណេសូតា—អក្សរសាស្ត្រអង់គ្លេស*។ ALDs សម្រាប់ការអនុវត្តការបរិយាយតេស្តបីរំពឹងទុកថាខុសគ្នាយ៉ាងខ្លាំងអាស្រ័យលើចំនួនសិស្សធ្វើតេស្ត អ្វីដែលត្រូវបានវាយតម្លៃក្នុងការធ្វើតេស្ត និងរបៀបដែលត្រូវបានវាយតម្លៃ។

ការវាយតម្លៃការយល់ដឹង មីណេសូតា —សេរី III (MCA)

អំណាន MCA គឺត្រូវបានផ្តល់ទៅឲ្យសិស្សទៅតាមចំនួនសិស្សទូទៅ ។ សិស្សទាំងអស់ ប៉ុន្តែសិស្សមួយភាគតូចនៅថ្នាក់ទី 3-8 និងថ្នាក់ទី 10 ធ្វើអំណាន MCA ។ សិស្សភាគច្រើនដែលទទួលបានសេវាកម្មសិក្សាពិសេសធ្វើតេស្តនេះ ជាការវាយតម្លៃអំណានសម្រាប់គោលបំណងគណនេយ្យភាព។

ការវាយតម្លៃការយល់ដឹង មីណេសូតា - ដែលបានកែប្រែ (MCA-Modified)

អំណាន MCA-Modified គឺជាការវាយតម្លៃជំនួសផ្អែកលើបទដ្ឋានលទ្ធផលដែលបានកែប្រែ។ ក្រុមកម្មវិធីអប់រំដោយខ្លួន (IEP) អាចជ្រើសរើសការវាយតម្លៃនេះ សម្រាប់សិស្សដែលមានកម្សោយដែលរារាំងដល់ការបង្ហាញសមត្ថភាពរបស់ពួកគេស្តីពី MCA។ MCA-Modified ផ្អែកលើព័ត៌មានលម្អិតអំពីការធ្វើតេស្ត ដូចជា MCA ប៉ុន្តែភាព លំបាករបស់តេស្ត និងថេរវេលាត្រូវបានកាត់បន្ថយ។ សហរដ្ឋអាមេរិក ក្រសួងអប់រំកំពុងកាត់បន្ថយការឧបត្ថម្ភសម្រាប់ការវាយតម្លៃនេះ ហើយការរៀបចំលើកចុងក្រោយរបស់ខ្លួននៅ មីណេសូតានឹងធ្វើនៅនិទាឃរដូវ ឆ្នាំ 2014។

តេស្ត មីណេសូតា នៃជំនាញការសិក្សា (MTAS)

អំណាន MTAS គឺជាការវាយតម្លៃជំនួសផ្អែកលើបទដ្ឋានលទ្ធផលជំនួស។ ក្រុម IEP អាចជ្រើសរើសការវាយតម្លៃ នេះសម្រាប់សិស្សដែលកម្សោយខាងខួរក្បាលធ្ងន់ធ្ងរបំផុត។ អំណានព័ត៌មានលម្អិតអំពីការធ្វើតេស្ត MTAS ផ្អែកលើចំនួនដែលត្រូវបានកាត់បន្ថយនៃបទដ្ឋានកម្រិតថ្នាក់ដែលបានកំណត់ដោយ MCA និង MCA-Modified។ ការជ្រើសរើសបទដ្ឋានទាំងនេះត្រូវបានកាត់បន្ថយតាមជម្រៅ ទំហំ និងភាពស្មុគស្មាញ។

បទដ្ឋានលទ្ធផល

តាមការរៀបចំដំបូងនៃការវាយតម្លៃថ្មី ក្រសួងអប់រំមីណេសូតាត្រូវការកិរិយាប្រជុំ អ្នកជំនាញតាមមុខវិជ្ជា និងអ្នកពាក់ព័ន្ធ ដើម្បីកំណត់កម្រិតនៃការអនុវត្តដែលត្រូវបានរាយការណ៍ទៅឲ្យសិស្ស មាតាបិតា និងសាលា តាមរយៈដំណើរការនៃការរៀបចំបទដ្ឋាន ។ គណៈកម្មាការរៀបចំបទដ្ឋានកំណត់ពិន្ទុដែលបានកាត់ដែលបង្ហាញកម្រិតចំនួនបួននៃលទ្ធផលពីការវាយតម្លៃទូទាំងរដ្ឋមីណេសូតា។ កម្រិតលទ្ធផលសម្រាប់ការវាយតម្លៃទូទៅដែលបានកែប្រែ និងជំនួសត្រូវបានបង្ហាញក្នុងតារាងលេខ 1 ។

តារាង 1. កម្រិតលទ្ធផលចាត់ជា

MCA	MCA-Modified	MTAS
មិនបំពេញតាមបទដ្ឋាន	មិនបានបំពេញតាមបទដ្ឋានលទ្ធផលដែលបាន កែប្រែ	មិនបំពេញតាមបទដ្ឋានលទ្ធផលជំនួស
បំពេញតាមបទដ្ឋានបានមួយភាគ	បំពេញតាមបទដ្ឋានលទ្ធផលដែលបានកែប្រែបានមួយផ្នែក	បំពេញតាមបទដ្ឋានលទ្ធផលជំនួសបានមួយផ្នែក
បំពេញតាមបទដ្ឋាន	បំពេញតាមបទដ្ឋានលទ្ធផលដែលបានកែប្រែ	បំពេញតាមបទដ្ឋានលទ្ធផលជំនួស
លើសពីបទដ្ឋាន	លើសពីបទដ្ឋានលទ្ធផលដែលត្រូវបានកែប្រែ	លើសពីបទដ្ឋានលទ្ធផលជំនួស

សិស្សដែលសម្រេចបាន "បំពេញតាម" និង "លើស" កម្រិតពី MCA MCA-Modified ឬ MTAS ត្រូវចាត់ទុកថាមានសមត្ថភាពគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងចំណេះដឹង ជំនាញ និងដំណើរការ (KSPs) ដែលបានបរិយាយក្នុងបទដ្ឋានការសិក្សា។

កម្មវិធីបរិយាយកម្រិតលទ្ធផល (ALDs) សម្រាប់ការវាយតម្លៃ មីណេសូតា នៅក្នុងអំណានដែលផ្តល់ការបរិយាយអំពីការអនុវត្តរបស់សិស្សតាមកម្រិតថ្នាក់សម្រាប់កម្រិតលទ្ធផលនីមួយៗ។ ផ្នែកអំណានៃបទដ្ឋានការសិក្សាអក្សរ សាស្ត្រ ភាសាអង់គ្លេសមីណេសូតាបង្ហាញត្រួសៗពីគោលបំណងការងាររបស់សិស្ស និងគ្រូចំពោះមុខវិជ្ជាក្នុងឆ្នាំសិក្សា។ ការវាយតម្លៃមីណេសូតាវាស់ស្ទង់ការទទួលបានគោលដៅរៀនរបស់សិស្ស ហើយ ALDs ពន្យល់ពីការអនុវត្តរបស់សិស្សតាមកម្រិតថ្នាក់ក្នុងកម្រិតនីមួយៗនៃលទ្ធផលអាស្រ័យលើលទ្ធផលការវាយតម្លៃ។ សិស្សដែលមានសមត្ថភាពគ្រប់គ្រាន់ពីការវាយតម្លៃមីណេសូតាត្រូវចាត់ទុកថាឆ្លងកាត់ជោគជ័យក្រោយមធ្យមសិក្សា ហើយការអ៊ីងទុកខ្ពស់នេះបង្ហាញឲ្យឃើញនៅក្នុង ALDs សម្រាប់ការអនុវត្តក្នុង "បំពេញតាម" និង "លើស" កម្រិតលទ្ធផល។ សិស្សដែលជាអ្នកអានមានសមត្ថភាពគ្រប់គ្រាន់ដោយការវាស់ស្ទង់នេះ គឺនៅលើផ្លូវដ៏ណលនឹងចាកចេញពីវិទ្យាល័យដោយមានការត្រៀមយ៉ាងល្អ សម្រាប់ចូលក្នុងកម្រិតការងារដោយគ្មានការជួយនៅក្នុងការអប់រំ ឬការបណ្តុះបណ្តាលក្រោយមធ្យមសិក្សា។ ដូចដែលបានកត់សម្គាល់ក្នុង ALDs សម្រាប់ការវាយតម្លៃអំណាន មីណេសូតា ការត្រៀមរួចជាស្រេចក្រោយពេលមធ្យមសិក្សាសម្រាប់ការអប់រំ ការបណ្តុះបណ្តាល ឬការចូលរួមកម្លាំងការងារតំណាងឲ្យក្តីវិំពីងទុកផ្សេងៗសម្រាប់សិស្សដែលទទួលការវាយតម្លៃជំនួសពីការវាយតម្លៃទាំងនោះសម្រាប់សិស្សទទួលបានការវាយតម្លៃដែលគ្រប់គ្រងដោយចំនួនសិស្សនៅក្នុងសាលា។

មានកម្រិតនៃការអនុវត្តរបស់សិស្សត្រូវបានបង្ហាញនៅក្នុងកម្រិតលទ្ធផលនីមួយៗដែលបរិយាយដោយ ALDs។ ពេលដែលពួកគេសរសេរកម្មវិធីបរិយាយសម្រាប់ថ្នាក់នីមួយៗ និងកម្រិតលទ្ធផលនីមួយៗ សមាជិកក្រុមការងារអភិវឌ្ឍ ALD បានប្រមើលមើលពីការអនុវត្តរបស់សិស្សដែលធ្លាក់ចុះនៅពាក់កណ្តាលកម្រិត។ ដើម្បីចាប់យក KSPs ដែលញែកការអនុវត្តរបស់សិស្សនៅក្នុងកម្រិតមួយពីកម្រិតផ្សេងទៀតឲ្យខុសគ្នា ក៏ជាការចាំបាច់ផងដែរដើម្បីចងចាំការចាប់ផ្តើមនៃកម្រិតដែលខ្ពស់ និងទាបជាងក្នុងកម្រិតលទ្ធផលដើម្បីញែកកម្រិតឲ្យខុសគ្នាពីកម្រិតដែលកៀកគ្នាឲ្យបានគ្រប់គ្រាន់។

អំឡុងពេលដំណើរការការរៀបចំបទដ្ឋាន អ្នកជំនាញតាមមុខវិជ្ជា - ភាគច្រើនគឺជាអ្នកអប់រំ - បង្កើនតម្រូវការទីពីរនៃ ALD ដើម្បីប្រើប្រាស់សម្រាប់ការរៀបចំពិន្ទុដែលត្រូវកាត់។ ការងារពី ALDs នៅក្នុងឯកសារនេះ អ្នករៀបចំបទដ្ឋានពិពណ៌នាការអនុវត្តរបស់សិស្សដែល "គ្រាន់តែបំពេញតាមយ៉ាងលំបាក" លក្ខណៈវិនិច្ឆយសម្រាប់ការបញ្ចូលក្នុងកម្រិតលទ្ធផល។ "គ្រាន់តែបំពេញតាមបានយ៉ាងលំបាក" ឬការចាប់ផ្តើម ALDs និងការចេញលទ្ធផលពិន្ទុដែលត្រូវកាត់តំណាងឲ្យការអនុវត្តទាបដែលតម្រូវឲ្យឆ្លើយតបនឹងការអ៊ីងទុកកម្រិតលទ្ធផលដែលបានផ្តល់។

ផ្នែក អនុផ្នែក វិស័យជំនាញ និងបទដ្ឋាន

ដូចបានបង្ហាញខាងលើ ការវាយតម្លៃអំណានមីណេសូតា ធ្វើតេស្តអនុអំណាននៃ*មីណេសូតា K- 12 បទដ្ឋានសិក្សា-អក្សរសាស្ត្រអង់គ្លេស*។ ផ្នែកអំណានរួមមានអនុផ្នែកអំណានពីរ៖ អត្ថបទអក្សរសាស្ត្រ និងព័ត៌មាន។ អនុផ្នែកអត្ថបទអក្សរសាស្ត្រនិង/ ឬព័ត៌មានត្រូវធ្វើឯកសារយ៉ាងក្នុងបទដ្ឋានមួយនៃបទដ្ឋានចំនួន 10 បទដ្ឋានចំនួន 7 ក្នុងចំណោមបទដ្ឋានចំនួន 10 ត្រូវបានវាយតម្លៃស្តីពី MCA និង MCA-Modified។ បទដ្ឋានចំនួន 4 ក្នុងចំណោមបទដ្ឋានចំនួន 10 ត្រូវបានវាយតម្លៃស្តីពី MTAS។ បទដ្ឋានអំណានចំដែលត្រូវបានដកចេញពីការវាយតម្លៃទូទាំងរដ្ឋ មីណេសូតា មិនធ្វើឲ្យពួកគេធ្វើតាមបទដ្ឋានទេ ទម្រង់គេស្តខ្ទាតធំ និងត្រូវបានវាយតម្លៃដោយគ្រូប្រចាំថ្នាក់។

បទដ្ឋាន 10 ក្នុងអនុអំណានត្រូវបានចាត់ជាក្រុមតាមវិស័យជំនាញ។ តារាង 2 បង្ហាញរបៀបដែលអនុផ្នែក វិស័យ ជំនាញ និងបទដ្ឋានត្រូវបានដំណាងក្នុង ALDs ។

តារាង 2 ។ វិស័យជំនាញ បទដ្ឋាន និងអនុផ្នែកមានក្នុងការវាយតម្លៃសំណាន

វិស័យជំនាញ និងបទដ្ឋាន*	អនុផ្នែកដែលត្រូវបានវាយតម្លៃ	ការវាយតម្លៃ
គំនិតសំខាន់ និងព័ត៌មានលម្អិត		
បទដ្ឋាន 1	អត្ថបទអក្សរសាស្ត្រ និងព័ត៌មាន	MCA, MCA-Modified, MTAS
បទដ្ឋាន 2	អត្ថបទអក្សរសាស្ត្រ និងព័ត៌មាន	MCA, MCA-Modified, MTAS
បទដ្ឋាន 3	អត្ថបទអក្សរសាស្ត្រ និងព័ត៌មាន	MCA, MCA-Modified, MTAS
ភាពពុំច្បាស់ និងទេពសម្ព័ន្ធ		
បទដ្ឋាន 4	អត្ថបទអក្សរសាស្ត្រ និងព័ត៌មាន	MCA, MCA-Modified, MTAS
បទដ្ឋាន 5	អត្ថបទអក្សរសាស្ត្រ និងព័ត៌មាន	MCA, MCA-Modified, MTAS
បទដ្ឋាន 6	អត្ថបទអក្សរសាស្ត្រ និងព័ត៌មាន	MCA, MCA-Modified, MTAS
ការរួមបញ្ចូលចំណេះដឹង និងគំនិត		
បទដ្ឋាន 7	—	—
បទដ្ឋាន 8	មានតែអត្ថបទព័ត៌មានប៉ុណ្ណោះ	MCA, MCA-Modified
បទដ្ឋាន 9	—	—
ក្រិតនៃសំណាន និងកម្រិតអត្ថបទដ៏ស្មុគស្មាញ		
បទដ្ឋាន 10	—	—

*បទដ្ឋាន 7, 9 និង 10 ពាក់ព័ន្ធនឹងការងារ ឬគម្រោងបានពង្រីកដែលត្រូវបានវាយតម្លៃដោយគ្រូច្រើនដង។ ពួកគេមិនត្រូវបានរាប់បញ្ចូលក្នុងការវាយតម្លៃអំណានមីណេសូតា និងមិនត្រូវបានដោះស្រាយក្នុង ALDs។

ការបង្កើតកម្មវិធីបរិយាយកម្រិតលទ្ធផល

ក្រុមការងារបង្កើត ALD រួមមានបុគ្គលិកក្រសួងអប់រំមីណេសូតា ព្រមទាំងអ្នកអប់រំមីណេសូតា។ បន្ទាប់ពីក្រុមនេះបានសរសេរសេចក្តីពង្រាង ALDs សេចក្តីពង្រាងកម្រិតមួយត្រូវបានដាក់ឲ្យត្រួតពិនិត្យនៅ HumRRO ដែលជាអង្គភាពឯករាជ្យមួយ។ HumRRO ធ្វើការងារដែលបានពង្រីការងារដូចរាល់ក្នុងការវាយតម្លៃនៃកម្មវិធីកម្រិតលទ្ធផល និងការអនុវត្ត ព្រមទាំងការបញ្ចូលនៃចំណុចធ្វើតស្តទៅតាមបទដ្ឋាន។ សេចក្តីពង្រាង ALDs និងការវាយតម្លៃនៃ HumRRO ត្រូវបានរៀបចំដើម្បីបង្ហាញទៅដល់គណៈកម្មការផ្តល់យោបល់បច្ចេកទេសរបស់មីណេសូតាដើម្បីត្រួតពិនិត្យ។ សេចក្តីពង្រាងទីពីររបស់ ALDs ត្រូវបានរៀបចំដោយការរួមបញ្ចូលអនុសាសន៍ដែលសមរម្យ។ សេចក្តីពង្រាងទីពីរត្រូវប្រើប្រាស់ក្នុងដំណើរការរៀបចំបទដ្ឋាន។ គណៈកម្មការរៀបចំបទដ្ឋានបានផ្តល់អនុសាសន៍ថាមិនមានការផ្លាស់ប្តូរសំខាន់ណាមួយចំពោះ ALDs ទេ ដូច្នេះ ALDs ត្រូវបានពិចារណាចុងក្រោយពេលស្នងការនៃការអប់រំអនុម័តអនុសាសន៍ពិនិត្យដែលបានកាត់របស់គណៈកម្មការរៀបចំបទដ្ឋាន។

បុគ្គលិកក្រសួងអប់រំ មីណេសូតា ក្នុងក្រុមការងារបង្កើត ALD មានអ្នកជំនាញការវាយតម្លៃអំណាន MCA ចំនួនពីររូប និងអ្នកជំនាញបទដ្ឋានការសិក្សាមួយរូប។ នាយក និងអ្នកគ្រប់គ្រងការវាយតម្លៃក្រសួងអប់រំមីណេសូតានៃការវាយតម្លៃជំនួសបានជួយសម្រួលដល់កិច្ចប្រជុំ។ បុគ្គលិកក្រសួងអប់រំមីណេសូតាត្រូវបានចូលរួមដោយគ្រូវិទ្យាល័យផ្នែកអក្សរសាស្ត្រអង់គ្លេស និងអ្នកសម្របសម្រួលអក្សរសាស្ត្រសម្រាប់ថ្នាក់បឋមសិក្សា។

មុនពេលចាប់ផ្តើមការងារ ក្រុមការងារបង្កើត ALD ត្រួតពិនិត្យសេចក្តីពង្រាង ALDs ដែលចេញដោយសមាគមវាយតម្លៃមានគុណភាពដ៏ជ្រៅ។ ក្រុមការងារពេញចិត្តការងាររបស់សមាគមវាយតម្លៃមានគុណភាពដ៏ជ្រៅ ធ្វើដើម្បីញែកឲ្យខុសគ្នាពីការចាប់ផ្តើមការអនុវត្តនៅកម្រិតខ្ពស់ជាងមុននីមួយៗបន្ថែមទៀតនៅលើការផ្តល់កម្មវិធីបរិយាយនៃកម្រិតរបស់ការអនុវត្ត។ ក្រុមការងារបង្កើត ALD ក៏សម្គាល់ជាមួយផលប្រយោជន៍កម្មវិធីបរិយាយគោលការណ៍របស់សមាគមសម្រាប់មហាវិទ្យាល័យ និងអាជីពនៅកម្រិតលទ្ធផលនីមួយៗក្នុងចំណោមកម្រិតលទ្ធផលបួនរបស់វា។

ព្រោះ ALDs ទាំងនេះមានសារសំខាន់ចំពោះដំណើរការរៀបចំបទដ្ឋានសម្រាប់ការវាយតម្លៃអំណាន ក្រុមការងារ ALD ផ្តោតជាសំខាន់លើបទដ្ឋានការសិក្សាសម្រាប់ព័ត៌មានលម្អិតតេស្តអំណាន និង MCA MCA-Modified និង MTAS ដើម្បីបង្កើតកម្មវិធីបរិយាយ។ សំណួរមួយចំនួនចាំបាច់ចំពោះដំណើរការ៖

1. តើអត្ថបទមានកម្រិតក្នុងភាពស្មុគស្មាញក្នុងកម្រិតតាមថ្នាក់ និងផ្លូងតាមកម្រិតថ្នាក់ដូចម្តេច?
2. តើកម្រិតអ្វីធ្វើឲ្យសិស្សធ្វើបាននៅក្នុងបទដ្ឋាននីមួយៗនៅកម្រិតលទ្ធផលនីមួយៗ?
3. តើចំពោះ KSPs ណាមួយដែលអាចបរិយាយលើការចាត់ថ្នាក់នៃការអនុវត្តទូទាំងបួនកម្រិត និងតើចំពោះ KSPs ណាមួយដែលមិនអាច?

4. យោងតាមព័ត៌មានលម្អិតពីការធ្វើតេស្ត តើសិស្សអាចបង្ហាញការធ្វើ KSPs របស់ពួកគេរបៀបណា?

ដោយចងចាំសំណួរទាំងនេះទុក អ្នកអភិវឌ្ឍន៍ ALD បានបង្កើតកម្មវិធីបង្ហាញដែលអាចគាំទ្រដោយភស្តុតាងនៅក្នុងការរៀបចំតេស្ត និងនៅក្នុងការអនុវត្តរបស់សិស្សលើការវាយតម្លៃទាំងនៅទូទាំងប្រទេស និងក្នុងថ្នាក់។ ការស្វែងយល់ពីចំណុចធ្វើតេស្តអាចទាញយកការយល់ដឹងមួយភាគពីអត្ថបទសម្រង់សម្រាប់អំណាន និងការស្វែងយល់ពីការវិភាគតាមអត្ថបទគឺជាចំណុចសំខាន់ចំពោះដំណើរការនៃការបង្កើត ALDs។ ការផ្លាស់ប្តូរដែលអាចរៀបចំក្នុងចំណុចធ្វើតេស្តបានរួមមានកម្រិតនៃភាពជាក់លាក់ ឬសេចក្តីសង្ខេបចំពោះសិស្សដែលត្រូវហ្វឹកហ្វឺនបន្ថែម ចំនួននៃការគាំទ្រផ្តល់ដោយផ្ទាល់ ឬតាមរយៈការប្រើពាក្យដោយប្រុងប្រយ័ត្ន និងការបញ្ចូលដើម្បីវាស់ស្ទង់ពីសមត្ថភាពចំណេះដឹង។ វាក៏មានសារសំខាន់ដែរក្នុងការយល់ដឹងថាកម្រិតធាតុផ្សំនៃ KSPs កំណត់ពីវិសាលភាពដែលពួកគេអាចអត្ថធិប្បាយផ្លូងតាមការបន្ត្ពាន់នៃកម្រិតលទ្ធផលសិក្សាណាខ្លះ។ អាចញែកកម្រិតទាំងបួននៃការអនុវត្តនៅក្នុង KSPs ជាច្រើនបាន ប៉ុន្តែមិនអាចនៅកន្លែងផ្សេងបានទេ។ ឧទាហរណ៍ ចំពោះ KSPs ខ្លះ យើងរំពឹងអាយសិស្សបង្ហាញពីចំណេះដឹងនៅក្នុងកម្រិត "បំពេញបាន" ហើយ KSP នឹងមិនបញ្ចប់ទៅក្នុងកម្មវិធីបង្ហាញពី "ការបំពេញលើស" ទេ។ ឧទាហរណ៍មួយទៀត KSP អាចនឹងមិនប្រើប្រាស់ដើម្បីស្វែងរកភាពខុសគ្នានៅក្នុងកម្រិតនៃការអនុវត្តទេ។ ក្នុងករណីនេះ KSP អាចនឹងលិចឡើងតែក្នុងកម្រិត "បំពេញបាន" តែប៉ុណ្ណោះ ហើយសិស្សអាចនឹងធ្វើបាន ឬធ្វើមិនបាន។

ការសន្ទតសំខាន់នៅក្នុងការអភិវឌ្ឍនៃអំណាន ALDs ទាំងនេះគឺថាអត្ថបទកើនឡើងនូវភាពស្មុគស្មាញ និងភាពលំបាកជាមួយនឹងកម្រិតនៃភាពជោគជ័យ។ ទោះបីជាមានកម្មវិធីបង្ហាញដូចគ្នា ឬប្រហាក់ប្រហែលចំពោះកម្រិតមួយចំនួនក៏ដោយ គេអាចយល់ឃើញថាសៀវភៅអានសម្រាប់សិស្សដែលប្រើប្រាស់ដើម្បីបង្ហាញជំនាញទាំងនេះ គឺកាន់តែមានភាពលំបាក។

ក្រុមអភិវឌ្ឍន៍ ALD បានធ្វើសេចក្តីព្រាងអំពី MCA ALDs ក្នុងរយៈពេលធ្វើការចំនួនប្រាំមួយវគ្គ។ ក្នុងអំឡុងពេលនៃវគ្គទាំងនោះ ក្រុមការងារយោងតាមបទដ្ឋានសិក្សា និងលក្ខខណ្ឌធ្វើតេស្តជាញឹកញាប់ ដូចបានកំណត់ចំណាំខាងលើ។ ក្រុមការងារក៏ផ្អែកលើភាសានៃ Webb's Depth នៃទំហំចំណេះដឹងដើម្បីពិពណ៌នាអំពីភាពស្មុគស្មាញនៃចំណេះដឹង និងផ្អែកលើរង្វាស់ Lexile ដើម្បីបង្កើតអាយមានការពិភាក្សាពីភាពស្មុគស្មាញ និងភាពលំបាកនៃអត្ថបទ។ ទស្សនៈជាច្រើនត្រូវបានបង្ហាញនៅក្នុងវគ្គការងារ និងមានការពិភាក្សាយ៉ាងសកម្ម។ ក្រុម ALD បានចាប់ផ្តើមធ្វើការលើកម្រិតថ្នាក់ទីមួយៗដោយដំបូងពិពណ៌នាពីការអនុវត្តដែល "បំពេញបានតាមបទដ្ឋាន" នៃសិស្សខាងអក្សរសាស្ត្រ និងអត្ថបទព័ត៌មាន។ កម្រិត "បំពេញបាន" បែងចែកការអនុវត្តដែលសមត្ថភាពចេញពីការអនុវត្តដែលមានសមត្ថភាពមួយភាគ ឬមិនមានសមត្ថភាពតែម្តង។ ព្រោះការវាយតម្លៃអំណានត្រូវបានកំណត់ដើម្បីញែកភាពខុសគ្នាវាងភាពមានសមត្ថភាព និងមិនសូវមានសមត្ថភាព មានភស្តុតាងច្រើនទៀតនៃការអនុវត្ត របស់សិស្សក្នុងការទាញយកផលប្រយោជន៍ក្នុងកម្រិតលទ្ធផលនេះ។ វាក៏មានសារសំខាន់ក្នុងការអភិវឌ្ឍសេចក្តីអធិប្បាយដែលមានភាពត្រឹមត្រូវនៃកម្រិត "បំពេញបាន" ដោយហេតុថាវាចាំបាច់ណាស់សម្រាប់គោលបំណងនៃគណនេយ្យភាព។ បន្ទាប់ពីបរិយាយអំពី "ការបំពេញបានតាមបទដ្ឋាន"ក្រុម ALD បានបង្ហូរចំណាប់អារម្មណ៍ទៅលើ "ការបំពេញលើសបទដ្ឋាន" វិញ ហើយបន្ទាប់មក ធ្វើការតាមលំដាប់លើ "ការបំពេញបានមួយភាគ" និង "ការមិនអាចបំពេញបាន" ។

សេចក្តីព្រាង ALDs ដែលបានលទ្ធផលពីវគ្គការងារទាំងនេះ ត្រូវបានពិនិត្យ និងកែសម្រួលជាបន្តបន្ទាប់ដោយអ្នកជំនាញវាយតម្លៃអំណានរបស់ MDE ដើម្បីប្រាកដថា គោលបំណង និងសេចក្តីអធិប្បាយរបស់ក្រុមត្រូវបានធ្ជុះបញ្ចាំងនៅក្នុងកម្មវិធីបង្ហាញដោយត្រឹមត្រូវ។ ពួកគេបានពិនិត្យម្តងទៀតនូវសំនួនសេចក្តីនៃកម្មវិធីបង្ហាញតាមរយៈកម្រិតលទ្ធផលតាមថ្នាក់ ដូចជាសំនួនសេចក្តីនៃកម្រិតលទ្ធផលនីមួយៗទាំងបួននៃថ្នាក់ទាំងអស់។ ម្យ៉ាងវិញទៀត តើសេចក្តីអធិប្បាយនូវអ្វីដែលសិស្សដឹង និងអាចធ្វើបាន កើនយ៉ាងត្រឹមត្រូវចេញពី "មិនបំពេញតាមបទដ្ឋាន" ដល់ "បំពេញលើសពីបទដ្ឋាន" នៅក្នុងថ្នាក់ដែរឬទេ? តើសេចក្តីអធិប្បាយនូវអ្វីដែលសិស្សដឹង និងអាចធ្វើបាននៅកម្រិតដូចជា "បំពេញបានតាមបទដ្ឋាន" បានកើនយ៉ាងត្រឹមត្រូវតាមថ្នាក់ដែរឬទេ?

បន្ទាប់ពីសេចក្តីព្រាង MCA ALDs ត្រូវបានបញ្ចប់ បុគ្គលិកវាយតម្លៃជំនួសនៅ MDE បានប្រើប្រាស់ ALDs ជាចំណុចចាប់ផ្តើមសម្រាប់ MCA-Modified និង MTAS ALDs ។ MCA-Modified គឺស្របតាមបទដ្ឋានសិក្សាដូច MCA ។ បទបញ្ជារបស់ MCA-Modified តម្រូវឲ្យបទដ្ឋានកម្រិតថ្នាក់ទទួលការវាយតម្លៃ ប៉ុន្តែអនុញ្ញាតឲ្យរដ្ឋបង្កើនការទទួលយកបានសម្រាប់សិស្សដែលកម្សោយសមត្ថភាព និងរៀបចំបទដ្ឋានលទ្ធផលដែលបានកែប្រែ។ ការដែលអាចទទួលយកគឺត្រូវបានដោះស្រាយនៅ MCA-Modified ដោយកាត់បន្ថយភាពស្មុគស្មាញ និងចំនួនអត្ថបទសម្រង់ដែលសិស្សត្រូវតែអាន និងដោយការផ្តល់សំណួរធ្វើតេស្តតិចជាងមុន។ បន្ថែមពីលើនេះ ចំណុចមួយចំនួនត្រូវបង្កប់ក្នុងអត្ថបទសម្រង់ ចំណុចមានជម្រើសចម្លើយចំនួនបីជាជាងបួន ហើយនិងគោលការណ៍ណែនាំភាសាត្រូវបានអនុវត្តយ៉ាងប្រុងប្រយ័ត្ន។ បទដ្ឋានលទ្ធផលដែលកែសម្រួលសម្រាប់ចំនួនសិស្សខ្សោយ ធ្វើឲ្យសិស្សមានសមត្ថភាព ពេលបង្ហាញចំនួនកាត់បន្ថយ KSPs ជាមួយកម្រិតទាបជាងមុននៃភាពស្មុគស្មាញនៃការយល់ដឹង។

MTAS ALDs អាស្រ័យលើបទដ្ឋាន 1 ដល់ 4 ដែលត្រូវបានកាត់បន្ថយ យ៉ាងស៊ីជម្រៅ ទំហំ និងស្មុគស្មាញ។ MDE សំដៅលើបទដ្ឋានទាំងនេះ "បទដ្ឋានដែលបានពង្រីក" ពីព្រោះលំដាប់ទាបនៃការអនុវត្តដែលបានរំពឹងលើបទដ្ឋានទាំងនេះ ត្រូវបានពង្រីកទៅក្រោមរួមបញ្ចូលទាំងជំនាញមូលដ្ឋាននៃភាពស្មុគ្រស្មាញការយល់ដឹងទាប។ បុគ្គលិកវាយតម្លៃជំនួសរបស់ MDE បានសរសេរ MTAS ALDs ចុងក្រោយ និងពឹងផ្អែកយ៉ាងខ្លាំងលើលក្ខខណ្ឌធ្វើតេស្តដែលបទដ្ឋានដែលពង្រីកគឺត្រូវបានបរិយាយ (មើណេសូតា មិនបោះពុម្ពផ្សាយបទដ្ឋានអប់រំជំនួស) ។

ការបញ្ជាប់ ALDs

ALD ត្រូវបានបង្ហាញទៅកាន់គណៈកម្មរៀបចំបទដ្ឋានៅខែ មិថុនា ឆ្នាំ 2013 ជាងកសារគោលនយោបាយ។ វាគឺជាបំណងរបស់រដ្ឋដែលសិស្សសម្រេចនៅកម្រិតដែលមានសមត្ថភាពដែលបានផ្តល់ អាចបង្ហាញចំណេះដឹង ជំនាញ និងដំណើរការបរិយាយនៅ ALD ទាំងនេះ និងគោលបំណងនៃការរៀបចំបទដ្ឋានគឺមិនបានពិនិត្យឡើងវិញ ឬកែសម្រួលឯកសារនេះទេ ប៉ុន្តែអនុវត្តការកំណត់ពីពិន្ទុដែលត្រូវកាត់។ គណៈកម្មការរៀបចំបទដ្ឋានគឺត្រូវតម្រូវឲ្យបង្កើតកម្មវិធីបង្ហាញចំណុចចាប់ផ្តើម ឬ "គ្រាន់តែបំពេញបានទាំងលំបាក" ពី ALDs ទាំងនេះ និងដើម្បីប្រើទៅលើការអនុវត្តដែលពួកគេបានឃើញថាបានបង្ហាញនៅក្នុងសម្ភារៈរៀបចំបទដ្ឋាន។ គណៈកម្មការអៀបចំបទដ្ឋានបានរាយការណ៍ថា គ្មានបញ្ហាជាមួយនឹងការពិពណ៌នាពីការអនុវត្តនៅគ្រប់កម្រិតនៃ ALDs ។ បន្ទាប់មក ALDs ត្រូវបញ្ចប់នៅពេលស្មុងការអប់រំបានអនុម័តលើពិន្ទុដែលបានកាត់ដែលបានណែនាំដោយគណៈកម្មាការអៀបចំបទដ្ឋាន។

ណែនាំឲ្យយល់ពីកម្មវិធីបរិយាយកម្រិតលទ្ធផល MCA-Modified នៃអំណាន

កម្មវិធីកម្រិតលទ្ធផល (ALDs) ចុះបញ្ជីក្នុងកម្រិតលទ្ធផលបួនទីមួយ១ខាងក្រោមបរិយាយអំពីចំណេះដឹង និងជំនាញដែលវាយតម្លៃលើការវាយតម្លៃការយល់ដឹងមីណេស្សូតា-ដែលកែប្រែ (MCA-Modified) ក្នុងអំណាន។

ពាក្យដែលមានប្រយោជន៍សម្រាប់ការយល់ដឹងពីរចនាសម្ព័ន្ធនៃកម្មវិធីបរិយាយកម្រិតលទ្ធផល (ALDs) និងអ្វីដែលពួកគេតំណាងឲ្យ

ALD៖ បរិយាយពីការអនុវត្តរបស់សិស្សនៅកម្រិតលទ្ធផលជាក់លាក់បួនទីមួយ១ដែលទាក់ទងទៅនឹងជំនាញអំណានពិសេស។ ALD អាចត្រូវបានចាត់ជាកម្រិតលទ្ធផលមួយក្នុងចំណោមកម្រិតលទ្ធផលបួន៖ មិនបានបំពេញតាមបទដ្ឋានលទ្ធផលដែលបានកែប្រែ បំពេញតាមបទដ្ឋានលទ្ធផលមួយផ្នែក បំពេញតាមបទដ្ឋានលទ្ធផលដែលបានកែប្រែ លើពីបទដ្ឋានលទ្ធផលដែលបានកែប្រែ។ សូមមើលការបរិយាយចុះបញ្ជីនៅក្រោមចំណងជើងនៃកម្រិតលទ្ធផលទីមួយ១។

ផ្នែក៖ នេះគឺជាផ្នែកតាមមុខវិជ្ជាដែលស្ថិតក្រោមការវាយតម្លៃ។ ចំណងជើងនៃផ្នែកសម្រាប់គេស្តMCA-Modified នៃជំនាញអប់រំមីណេស្សូតាគឺ**អំណាន**។

អនុផ្នែក៖ បទដ្ឋានអំណានត្រូវបានរៀបចំស្ថិតក្រោមអនុប្រភេទដែលបានហៅថាអនុផ្នែក។ អនុផ្នែកពីរបានវាយតម្លៃលើ Reading MCA-Modified គឺជាអត្ថបទអក្សរសាស្ត្រ និងព័ត៌មាន។ ការបរិយាយនៃប្រភេទអត្ថបទដែលបានរកឃើញនៅក្នុងអនុផ្នែកទាំងនេះត្រូវបានយកពី MCA-III ថ្នាក់ទី 3–8, 10 និង MCA-Modified ថ្នាក់ទី 5–8, 10 DRAFT Test Specifications អំណាន (បទដ្ឋានឆ្នាំ 2010) ទំព័រទី 3-4 និង 15 ដែលត្រូវបានរកឃើញនៅលើគេហទំព័រក្រសួងអប់រំមីណេស្សូតា។ [ពិនិត្យមើល MCA-III ថ្នាក់ទី 3–8, 10 និង MCA-Modified ថ្នាក់ទី 5–8, 10 DRAFT Test Specifications៖ អំណាន (បទដ្ឋានឆ្នាំ 2010))]។

1. អក្សរសាស្ត្រ៖ អត្ថបទដែលមានពាក្យស្របទៅតាមអនុផ្នែកអក្សរសាស្ត្រអាចរួមមានដូចជា ប្រភេទអត្ថបទដូចខាងក្រោម៖ រឿង និងកំណាព្យ។
2. អត្ថបទព័ត៌មាន៖ អត្ថបទដែលមានពាក្យស្របទៅតាមអនុផ្នែកអត្ថបទព័ត៌មានរួមមានដូចជាប្រភេទអត្ថបទដូចខាងក្រោម៖ អត្ថបទពិតនៃអក្សរសាស្ត្រប្រវត្តិសាស្ត្រ និងវិទ្យាសាស្ត្រ។

បទដ្ឋាន៖ បទដ្ឋានផ្តល់ពីការបរិយាយចំណេះដឹង និងជំនាញទូទៅក្នុងអំណានដែលសិស្សទាំងអស់ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវរបស់រដ្ឋ។ បទដ្ឋានទាំងអំណានប្រាំពីរក្នុងចំណោមដប់ត្រូវបានវាយតម្លៃលើ Reading MCA-Modified ។

វិស័យជំនាញ៖ វិស័យជំនាញជាការចាត់ប្រភេទនៃបទដ្ឋានទូទៅទាក់ទងនឹងអំណានដូចបានបង្ហាញក្នុងបទដ្ឋានអប់រំ K-12 មីណេស្សូតា ក្នុងអក្សរសាស្ត្រអង់គ្លេស (ឆ្នាំ 2010) ដែលត្រូវរកឃើញនៅលើគេហទំព័រក្រសួងអប់រំមីណេតា។ [ពិនិត្យមើលបទដ្ឋានអប់រំ K-12 មីណេស្សូតាក្នុងអក្សរសាស្ត្រអង់គ្លេស(2010)]។

វិស័យជំនាញបីក្នុងចំណោមវិស័យជំនាញបួនត្រូវបានវាយតម្លៃនៅលើ MCA-Modified៖

1. គំនិត និងព័ត៌មានលម្អិតសំខាន់ៗ (បទដ្ឋាន 1, 2, 3៖ ខ. ភស្តុតាងអត្ថបទ ធ្វើការសរុបសេចក្ដី គំនិតសំខាន់ រឿងខ្លីៗ លក្ខណៈពិសេសនៃអត្ថបទ និងការប្រាប់ចរិតលក្ខណៈបុគ្គលម្នាក់ៗ ព្រឹត្តិការណ៍ គំនិត)
2. ហេតុកម្ម និងចនាសម្ព័ន្ធ (បទដ្ឋាន 4, 5, 6 ៖ ខ. ពាក្យ ភាសាប្រៀបធៀប ទម្រង់អត្ថបទ គោលបំណងរបស់អ្នកនិពន្ធ រចនាបទ និងវិធីសាស្ត្ររបស់អ្នកនិពន្ធ)
3. ការរួមបញ្ចូលចំណេះដឹង និងគំនិត (បទដ្ឋាន 8 មានតែអនុផ្នែកអត្ថបទព័ត៌មាន៖ ខ. ភាពជឿជាក់ និងវិធីសាស្ត្របង្ហាញភស្តុតាងរបស់អ្នកនិពន្ធ)

ALDs ចុះបញ្ជីក្នុងកម្រិតលទ្ធផលទីមួយ១ចំនួនបួនអាចអនុវត្តចំពោះបទដ្ឋានមួយ ឬច្រើនក្នុងវិស័យជំនាញ។ ប្រសិនបើលក្ខណៈពិសេសនៃជំនាញផ្តល់ឲ្យមិនផ្ទាស់ប្តូរពីកម្រិតលទ្ធផលមួយទៅកម្រិតលទ្ធផលបន្ទាប់ទេ ជំនាញមិនត្រូវបានរៀនឡើងវិញក្នុងកម្រិតបន្ទាប់ខ្ពស់ជាងនេះទេ។ ALDs រួមទាំងថ្នាក់ទាំងអស់ដែលបានរៀនឡើងវិញ បរិយាយជំនាញដែលបានប្រើឲ្យអត្ថបទលំបាកស្មុគស្មាញជាមួយកម្រិតដែលជោគជ័យទីមួយ១។

ថ្នាក់ 5 - កម្មវិធីបរិយាយកម្រិតលទ្ធផលដែលត្រូវបានកែតម្រូវ

មិនបំពេញតាមបទដ្ឋានលទ្ធផលដែលបានកែតម្រូវ

នៅពេលធ្វើអត្ថកម្មជាមួយអត្ថបទអក្សរសាស្ត្រ និងព័ត៌មាន សិស្សនៅក្នុងកម្រិតលទ្ធផលនេះបង្ហាញពីជំនាញនានាមានលក្ខណៈមិនអូចគ្នា និងដោយមានភាពត្រឹមត្រូវតិចតួច។

គំនិត និងព័ត៌មានលម្អិតសំខាន់ៗ (បទដ្ឋាន 1, 2, 3)

- កំណត់គំនិតសំខាន់/សារសំខាន់ដែលបានបង្ហាញឲ្យបានច្បាស់លាស់ក្នុងអំណានអត្ថបទសម្រង់
- រំលឹកព័ត៌មានលម្អិតពីអំណានអត្ថបទសម្រង់
- កំណត់ពីអារម្មណ៍របស់តួអង្គក្នុងអំណានអត្ថបទសម្រង់
- ធ្វើការស្មានធម្មតាដោយផ្អែកលើព័ត៌មានក្នុងអំណានអត្ថបទសម្រង់
- កំណត់ពីគំនិតដែលបានបង្ហាញឲ្យបានច្បាស់ក្នុងអត្ថបទ
- កំណត់ពីលំដាប់លំដោយព្រឹត្តិការណ៍ក្នុងអំណានអត្ថបទសម្រង់

ហេតុកម្ម និងធនាសម្ព័ន្ធ (បទដ្ឋាន 4, 5, 6)

- កំណត់ទីតាំងតម្រុយបរិបទច្បាស់លាស់ក្នុងអត្ថបទដើម្បីយល់ពីអត្ថន័យនៃពាក្យ
- កំណត់ទីតាំងពាក្យបច្ចេកទេសដែលបានរៀនក្នុងអត្ថបទតាមមុខវិជ្ជា
- កំណត់ទីតាំងពាក្យភ្ជាប់សេចក្តីច្បាស់លាស់ (ឧ. និង ប៉ុន្តែ ភ្លាមៗនោះ ជាធម្មតា)
- កំណត់គោលបំណងរបស់អ្នកនិពន្ធពេលបានបង្ហាញយ៉ាងច្បាស់ក្នុងអំណានអត្ថបទសម្រង់

ការរួមបញ្ចូលចំណេះដឹង និងគំនិត (បទដ្ឋាន 8 មានតែអត្ថុផ្នែកអត្ថបទព័ត៌មាន)

- កំណត់ភស្តុតាងច្បាស់លាស់ក្នុងអត្ថបទ (ឧ. ទំនាក់ទំនងសមហេតុផលរវាងប្រយោគ)

បំពេញតាមបទដ្ឋានលទ្ធផលដែលត្រូវបានកែតម្រូវតាមផ្នែក

នៅពេលរួមបញ្ចូលជាមួយអត្ថបទអក្សរសាស្ត្រ និងព័ត៌មាន សិស្សដែលស្ថិតនៅកម្រិតលទ្ធផលនេះបង្ហាញពីជំនាញនានា មានភាពអូចគ្នា និងត្រឹមត្រូវដែលបានកំណត់។

គំនិត និងព័ត៌មានលម្អិតសំខាន់ៗ (បទដ្ឋាន 1, 2, 3)

- បង្ហាញគំនិតសំខាន់/សារសំខាន់ ឬប្រធានបទពីផ្នែកនៃអំណានអត្ថបទសម្រង់ ឬពីអត្ថបទសម្រង់ទាំងស្រុង
- កំណត់ទីតាំងព័ត៌មានលម្អិតសំខាន់ៗក្នុងអំណានអត្ថបទសម្រង់
- ស្គាល់ធាតុនៃការប្រាប់ចរិតលក្ខណៈក្នុងអំណានអត្ថបទសម្រង់ (ឧ. អារម្មណ៍ ការលើកទឹកចិត្ត)
- ធ្វើការស្មានធម្មតាដោយផ្អែកលើព័ត៌មានក្នុងអំណានអត្ថបទសម្រង់
- កំណត់ផ្ទឹងពិត ឬយោបល់ផ្ទាល់ខ្លួនដែលបានបង្ហាញយ៉ាងច្បាស់ក្នុងអត្ថបទ
- លំដាប់លំដោយព្រឹត្តិការណ៍សំខាន់ៗក្នុងអំណានអត្ថបទសម្រង់
- ប្រើប្រាស់ភស្តុតាងអត្ថបទជាក់ស្តែងដើម្បីធ្វើសេចក្តីបញ្ជាក់ឲ្យសមហេតុផល
- នៅពេលមានហេតុត្រូវកំណត់ពីផល
- ធ្វើការប្រៀបធៀបធម្មតាដោយអាស្រ័យលើព័ត៌មានដែលបានបង្ហាញយ៉ាងច្បាស់ក្នុងអំណានអត្ថបទសម្រង់
- ស្គាល់ពាក្យអក្សរសាស្ត្រ (ឧ. តួអង្គ កាលអាកាស ស្ថានភាព)
- កំណត់ធាតុអក្សរសាស្ត្រនៃកាលអាកាស និងប្រធានបទ

ហត្ថកម្ម និងវចនានុក្រម (បទដ្ឋាន 4, 5, 6)

ប្រើប្រាស់តម្រុយបរិបទច្បាស់លាស់ក្នុងអត្ថបទដើម្បីយល់ពីអត្ថន័យនៃពាក្យ

កំណត់ពាក្យបច្ចេកទេសដែលបានរៀនក្នុងអត្ថបទតាមមុខវិជ្ជា

ប្រើប្រាស់ពាក្យបន្ថែមដើម និងពាក្យបន្ថែមចុងរួមដើម្បីកំណត់អត្ថន័យនៃពាក្យតាមកម្រិតថ្នាក់

កំណត់ពាក្យភ្ជាប់សេចក្តីច្បាស់លាស់ (ឧ. និង ប៉ុន្តែ ភ្លាមៗនោះ ជាធម្មតា)

ស្គាល់លក្ខណៈពិសេស ទម្រង់ និងមុខងារនៃអត្ថបទគោល

បង្ហាញពីគោលបំណងរបស់អ្នកនិពន្ធនៅពេលដែលបានបង្ហាញយ៉ាងច្បាស់ក្នុងអត្ថបទ

ស្គាល់ការប្រើប្រាស់អង្គអក្សរសាស្ត្រ (ឧ. អារម្មណ៍)

ការយល់ឃើញ ការយកចិត្តទុកដាក់ និងគំនិត (បទដ្ឋាន 8 មានតែអនុវត្តអត្ថបទព័ត៌មាន)

ធ្វើការវិនិច្ឆយអំពីការទទួលស្គាល់របស់អ្នកនិពន្ធដោយអាស្រ័យលើភស្តុតាងដែលបានបង្ហាញយ៉ាងច្បាស់ក្នុងអំណានអត្ថបទសម្រង់

បំពេញតាមបទដ្ឋានលទ្ធផលដែលត្រូវបានកែតម្រូវ

នៅពេលអត្ថរកម្មជាមួយអក្សរសាស្ត្រ និងអត្ថបទព័ត៌មាន សិស្សដែលស្ថិតនៅក្នុងកម្រិតលទ្ធផលនេះ បង្ហាញពីជំនាញនានាដោយមានលក្ខណៈអូចគ្នា និងត្រឹមត្រូវ។

គំនិត និងព័ត៌មានលម្អិតសំខាន់ៗ (បទដ្ឋាន 1, 2, 3)

សង្ខេបគំនិតសំខាន់/សារសំខាន់ ស្ថានភាព និងប្រធានបទពីផ្នែកនៃអត្ថបទសម្រង់ ឬអត្ថបទសម្រង់ទាំងស្រុង។

កំណត់ព័ត៌មានលម្អិតដែលគាំទ្រសេចក្តីបញ្ជាក់ពីអំណានអត្ថបទសម្រង់

កំណត់ការលើកទឹកចិត្ត និងអារម្មណ៍របស់តួអង្គ

បង្កើតការសរុបសេចក្តី និងការស្មានធម្មតាដោយអាស្រ័យលើព័ត៌មានជាក់ស្តែងក្នុងអំណានអត្ថបទសម្រង់

សេចក្តីសន្និដ្ឋានដែលគាំទ្រដោយភស្តុតាងគ្រប់គ្រាន់ក្នុងអំណានអត្ថបទសម្រង់

ញែកឲ្យខុសគ្នារវាងរឿងពិត និងយោបល់ផ្ទាល់ខ្លួននៅក្នុងអត្ថបទ

ព្រឹត្តិការណ៍ស្ថានភាពបន្តបន្ទាប់ ឬដំណាក់កាលដំណើរការ

ប្រើប្រាស់ភស្តុតាងអត្ថបទដើម្បីធ្វើសេចក្តីបញ្ជាប់ឲ្យសមហេតុផល

កំណត់ពីទំនាក់ទំនងហេតុ និងផលដែលបានបង្ហាញយ៉ាងច្បាស់ក្នុងអំណានអត្ថបទសម្រង់

ធ្វើការប្រៀបធៀបធម្មតាដោយអាស្រ័យលើព័ត៌មានដែលបង្ហាញយ៉ាងជាក់ស្តែងក្នុងអំណានអត្ថបទសម្រង់

កំណត់ពីពាក្យអក្សរសាស្ត្រ (ឧ. តួអង្គ កាលអាកាស ស្ថានភាព)

ហត្ថកម្ម និងវចនានុក្រម (បទដ្ឋាន 4, 5, 6)

ប្រើប្រាស់តម្រុយបរិបទក្នុងអត្ថបទដើម្បីយល់ពីអត្ថន័យនៃពាក្យ

ចាត់ថ្នាក់ពាក្យបច្ចេកទេសនៅក្នុងអត្ថបទតាមមុខវិជ្ជា

ប្រើពាក្យបន្ថែមដើម ពាក្យបន្ថែមចុង ពាក្យឫស ពាក្យគស់ ដើម្បីកំណត់អត្ថន័យនៃពាក្យតាមកម្រិតថ្នាក់

ប្រើពាក្យភ្ជាប់សេចក្តីច្បាស់លាស់ (ឧ. និង ប៉ុន្តែ ភ្លាមៗនោះ ក្រោយមកទៀត) ដើម្បីសម្គាល់ពាក្យភ្ជាប់សេចក្តីតាមបទដ្ឋាន

ភ្ជាប់ពាក្យដែលមានន័យបង្កប់ទៅនឹងអត្ថន័យ

កំណត់លក្ខណៈពិសេស ទម្រង់ និងមុខងារនៃអត្ថបទគោល

កំណត់គោលបំណងរបស់អ្នកនិពន្ធក្នុងអត្ថបទ

កំណត់អារម្មណ៍ (បរិយាកាសអារម្មណ៍) នៃអត្ថបទ

កំណត់អង្គអក្សរសាស្ត្រ (ឧ. អារម្មណ៍)

ការយល់ដឹងចំណេះដឹង និងគំនិត (បទដ្ឋាន 8 មានតែអនុវត្តអត្ថបទព័ត៌មាន)

វិនិច្ឆយភាពជឿជាក់របស់អ្នកនិពន្ធអាស្រ័យលើព័ត៌មានដែលបានបង្ហាញយ៉ាងច្បាស់ក្នុងអំណានអត្ថបទសម្រង់

- កំណត់ទីតាំងអំណះអំណាងច្បាស់លាស់ (ឧ. ព័ត៌មានលម្អិត ឧទាហរណ៍) ក្នុងអត្ថបទ
- កំណត់ភស្តុតាងដែលគាំទ្រអំណះអំណាង
- កំណត់ពីរបៀបអ្នកនិពន្ធបង្ហាញរឿងពិត និងយោបល់ផ្ទាល់ខ្លួន

លើសពីបទដ្ឋានលទ្ធផលដែលត្រូវបានកែតម្រូវ

នៅពេលរួមបញ្ចូលជាមួយអត្ថបទអក្សរសាស្ត្រ និងព័ត៌មាន សិស្សដែលស្ថិតនៅកម្រិតលទ្ធផលនេះបង្ហាញពីជំនាញនានាដែលមានកម្រិតខ្ពស់នៃភាពអូចគ្នា និងប្រសិទ្ធភាព។

គំនិត និងព័ត៌មានសំខាន់ (បទដ្ឋាន 1, 2, 3)

សង្ខេបគំនិតសំខាន់/សារសំខាន់ ព័ត៌មានលម្អិតគាំទ្រស្ថានភាពនិងប្រធានបទពីផ្នែកនៃអត្ថបទមួយឬពីអត្ថបទទាំងមូល

កំណត់ព័ត៌មានលម្អិតដែលពាក់ព័ន្ធដែលគាំទ្រ សេចក្តីបញ្ជាប់ ដែលបានដកស្រង់ពីអត្ថបទអំណាន

យល់ពីការលើកទឹកចិត្តនិងអារម្មណ៍របស់តួអង្គ

ប្រើប្រាស់ការសរុបសេចក្តីដើម្បីស្វែងអំពីអត្ថបទអំណាន

ធ្វើសេចក្តីសន្និដ្ឋានអំពីអត្ថបទអំណាន

ព្រឹត្តិការណ៍ស្ថានភាព តាមលំដាប់លំដោយព្រឹត្តិការណ៍ពិតជំហានក្នុងដំណើរការ

សេចក្តីបញ្ជាប់ដោយសមរម្យដោយផ្អែកលើព័ត៌មានបង្ហាញច្បាស់លាស់ក្នុងអំណានអត្ថបទសម្រង់

ប្រើប្រាស់ភស្តុតាងអត្ថបទដើម្បីយល់ការទំនាក់ទំនងហេតុនិងផល

ធ្វើការប្រៀបធៀបធម្មតាដោយផ្អែកលើភាពច្បាស់លាស់នៃព័ត៌មានក្នុងអំណានអត្ថបទសម្រង់

កំណត់ពាក្យអក្សរសាស្ត្រ(ឧ. ទឹកដែ អារម្មណ៍)

ហេតុការណ៍ និងរចនាសម្ព័ន្ធ (បទដ្ឋាន 4, 5, 6)

កំណត់គោលបំណងនៃពាក្យបច្ចេកទេសក្នុងអត្ថបទតាមមុខវិជ្ជា

ប្រើប្រាស់រូបសាស្ត្រ (រចនាសម្ព័ន្ធពាក្យ) ដើម្បីកំណត់អត្ថន័យរបស់ពាក្យ ឬឃ្លា

ប្រើប្រាស់ទំនាក់ទំនងពាក្យពាក្យនិងឃ្លាសំខាន់ៗដើម្បីយល់ពាក្យភ្ជាប់បទដ្ឋាន

សម្គាល់ពាក្យមានន័យបង្កប់ក្នុងបរិបទស្រដៀងគ្នា

វិភាគលក្ខណៈពិសេសសមរម្យ និងមុខងារអត្ថបទគោល

បង្ហាញគោលបំណងរបស់អ្នកនិពន្ធនិងអត្ថបទយោង

កំណត់អារម្មណ៍ (បរិយាកាសអារម្មណ៍) និងរចនាបទ (បច្ចេកទេសនិងវិធីសាស្ត្ររបស់អ្នកនិពន្ធទៅលើអត្ថន័យ ឧ. ជម្រើសនៃពាក្យនិងសំណង់ប្រយោគ)នៃអត្ថបទ

កំណត់អត្ថន័យនៃអង្គអក្សរសាស្ត្រ(ឧ. អារម្មណ៍ ទឹកដែ)

ការជួយបញ្ជាលចំណេះដឹង និងគំនិត (បទម្ពាន 8 មានតែអនុវត្តន៍ផ្នែកអត្ថបទព័ត៌មាន)

វិនិច្ឆយការជឿទុកចិត្តរបស់អ្នកនិពន្ធដោយផ្អែកលើព័ត៌មានដែលបានបង្ហាញច្បាស់លាស់ក្នុងអំណានអត្ថបទសម្រង់

- កំណត់ទីតាំង និងយល់អំពីអំណះអំណាង (ខ.ព័ត៌មានលម្អិតនិងទាហរណ៍)ក្នុងអត្ថបទ
- សម្គាល់ភស្តុតាងគ្រប់ គ្រាន់
- យល់ពីរបៀបដែលអ្នកនិពន្ធបង្ហាញជឿងពិតនិងមតិយោបល់

ថ្នាក់ទី 6 – កម្មវិធីកម្រិតលទ្ធផលដែលបានកែប្រែ

មិនបានបំពេញតាមបទដ្ឋានលទ្ធផលដែលបានកែប្រែ

នៅពេលធ្វើអន្តរកម្មជាមួយអត្ថបទអក្សរសាស្ត្រ និងព័ត៌មាន សិស្សនៅក្នុងកម្រិតលទ្ធផលនេះបង្ហាញពីជំនាញនានាមានលក្ខណៈមិនអូចគ្នា និងដោយមានភាពត្រឹមត្រូវតិចតួច។

គំនិត និងព័ត៌មានលម្អិតសំខាន់ៗ (បទដ្ឋាន 1, 2, 3)

- កំណត់គំនិតសំខាន់ដែលបានបង្ហាញយ៉ាងច្បាស់/សារសំខាន់នៃអត្ថបទអំណាន
- រំលឹកពីព័ត៌មានលម្អិតសំខាន់ពីអត្ថបទអំណាន
- កំណត់អារម្មណ៍របស់តួ អង្គក្នុងអត្ថបទអំណាន
- ធ្វើការទាយធម្មតាដោយផ្អែកលើព័ត៌មានជាក់ស្តែងក្នុងអត្ថបទអំណាន
- កំណត់ផ្សឹងពិតដែលបានបង្ហាញនៅក្នុងអត្ថបទ
- កំណត់ព្រឹត្តិការណ៍តាមលំដាប់លំដោយក្នុងអត្ថបទអំណាន
- ដកស្រង់សេចក្តីបញ្ចប់ដោយផ្អែកដែលបានគាំទ្រដោយព័ត៌មានក្នុងអត្ថបទអំណាន
- ស្គាល់ពីលទ្ធផល ពេលផ្តល់ហេតុផល

ហត្ថកម្ម និងវចនានុក្រម (បទដ្ឋាន 4, 5, 6)

- ប្រើប្រាស់តំរុយបរិបទជាគោលនៅក្នុងអត្ថបទដើម្បីយល់ពីន័យរបស់ពាក្យ
- កំណត់ពាក្យបច្ចេកទេសក្នុងអត្ថបទតាមមុខវិជ្ជា
- កំណត់ពាក្យភ្ជាប់ឱ្យច្បាស់ (ឧទាហរណ៍ ម្តងទៀត ផងដែរ ទោះជាយ៉ាងណា ត្រូវហើយ) នៅក្នុងអត្ថបទ
- កំណត់គោលបំណងរបស់អ្នកនិពន្ធនៅពេលបង្ហាញយ៉ាងច្បាស់នៅក្នុងអំណានអត្ថបទសម្រង់

ការយល់ដឹងចំណេះដឹង និងគំនិត (បទដ្ឋាន 8 មានតែអនុវត្តអត្ថបទព័ត៌មាន)

- បង្កើតការវិនិច្ឆយគោលអំពីការទទួលស្គាល់របស់អ្នកនិពន្ធដែលផ្អែកលើភស្តុតាងដែលបានបង្ហាញយ៉ាងច្បាស់នៅក្នុងអំណានអត្ថបទសម្រង់
- យល់ថាភស្តុតាងអាចប្រើប្រាស់ដើម្បីគាំទ្រអំណះអំណាង

បំពេញតាមបទដ្ឋានលទ្ធផលដែលបានកែតម្រូវមួយផ្នែក

នៅពេលរួមបញ្ចូលជាមួយអត្ថបទអក្សរសាស្ត្រ និងព័ត៌មាន សិស្សដែលស្ថិតនៅកម្រិតលទ្ធផលនេះបង្ហាញពីជំនាញនានា មានភាពអូចគ្នា និងត្រឹមត្រូវដែលបានកំណត់។

គំនិត និងព័ត៌មានលម្អិតសំខាន់ៗ (បទដ្ឋាន 1, 2, 3)

- ផ្ទេងពីគំនិតសំខាន់ និងសារសំខាន់ពីផ្នែកមួយនៃអត្ថបទសម្រង់ ឬអត្ថបទសម្រង់ទាំងអស់
- កំណត់ពីរបៀបព័ត៌មានលម្អិតគាំទ្រខ្លះគឺត្រូវបានភ្ជាប់ទៅសេចក្តីបញ្ចប់ពីអត្ថបទ
- ស្គាល់ចរិតលក្ខណៈ (ឧទាហរណ៍ អារម្មណ៍ មូលហេតុ)
- ចរិតលក្ខណៈផ្ទុយគ្នានៅក្នុងអំណានអត្ថបទសម្រង់
- ប្រើភស្តុតាងជាក់ស្តែងពីអត្ថបទ៖
  - ធ្វើសេចក្តីបញ្ចប់ដែលសមហេតុផល
  - ធ្វើការស្មានធម្មតា
  - កំណត់ពីទំនាក់ទំនងហេតុ/ផលធម្មតា
  - កំណត់ផ្សឹងពិត
  - ធ្វើការប្រៀបធៀបធម្មតា

ព្រឹត្តិការណ៍ជាបន្តបន្ទាប់តាមលំដាប់នៃកាលប្បវត្តិ

សម្គាល់ពាក្យអក្សរសាស្ត្រជាគោល (ឧ. អ្នកក្លាហាន ត្រចិត្តអាក្រក់ ។ល។)

កំណត់ពីធាតុអក្សរសាស្ត្រកាលអាកាស និងប្រធានបទ

ហត្ថកម្ម និងរចនាសម្ព័ន្ធ (បទដ្ឋាន 4, 5, 6)

ប្រើភស្តុតាងជាក់លាក់នៅក្នុងអត្ថបទដើម្បីយល់ពីអត្ថន័យនៃពាក្យ

កំណត់ពាក្យបច្ចេកទេសក្នុងអត្ថបទតាមមុខវិជ្ជា

ប្រើពាក្យដើម និងពាក្យឫសដើម្បីបង្ហាញពីអត្ថន័យនៃពាក្យពិបាកតាមកម្រិតថ្នាក់

កំណត់ពាក្យភ្ជាប់ និងឃ្លា (ឧ.ម្តងទៀត ផងដែរ ទោះជាយ៉ាងណា ត្រូវហើយ) ដើម្បីស្គាល់ពីពាក្យភ្ជាប់នៅក្នុងអត្ថបទ

ស្គាល់ពីលក្ខណៈពិសេស ទម្រង់ និងមុខងារនៃអត្ថបទមូលដ្ឋាន

បញ្ជាក់ពីគោលបំណងរបស់អ្នកនិពន្ធនៅពេលបង្ហាញយ៉ាងច្បាស់នៅក្នុងអត្ថបទ

កំណត់ឧបករណ៍អក្សរសាស្ត្រ (ឧ. ពាក្យប្រៀបធៀប ភាពផ្ទុច)

កំណត់អារម្មណ៍ (បរិយាកាសអារម្មណ៍) នៃអត្ថបទ

ការយល់ដឹងចំណេះដឹង និងគំនិត (បទដ្ឋាន 8 មានដែលតម្រូវអ្នកអត្ថបទពីព័ត៌មាន)

បង្កើតការវិនិច្ឆយអំពីភាពជឿជាក់របស់អ្នកនិពន្ធដែលផ្អែកលើការបង្ហាញភស្តុតាងយ៉ាងច្បាស់នៅក្នុង

អំណានអត្ថបទសម្រង់

- កំណត់អំណះអំណាងឱ្យច្បាស់ (ឧ. ព័ត៌មានលម្អិត ឧទាហរណ៍)នៅក្នុងអត្ថបទ
- កំណត់ភស្តុតាងអាចជឿជាក់ (ឧ. ការសម្ភាសន៍ជាមួយអ្នកជំនាញ ការស្រាវជ្រាវថ្មីៗ) ដែលគាំទ្រអំណះអំណាង
- ស្គាល់ពីរបៀបដែលអ្នកនិពន្ធបង្ហាញការពិត និងយោបល់ផ្ទាល់ខ្លួន

បំពេញតាមបទដ្ឋានលទ្ធផលដែលបានកែប្រែ

នៅពេលធ្វើអន្តរកម្មជាមួយអត្ថបទអក្សរសាស្ត្រ និងព័ត៌មាន សិស្សនៅកម្រិតលទ្ធផលនេះបង្ហាញពីជំនាញផ្ទុចនានាដោយមានលក្ខណៈផ្ទុចគ្នា និងត្រឹមត្រូវ។

គំនិត និងព័ត៌មានលម្អិតសំខាន់ៗ (បទដ្ឋាន 1, 2, 3)

សង្ខេបគំនិតសំខាន់/សារសំខាន់ ស្ថានភាព ប្រធានបទ និងមួយផ្នែកនៃអត្ថបទសម្រង់ ឬពីអត្ថបទសម្រង់ទាំងមូល

កំណត់ព័ត៌មានលម្អិតសំខាន់ដែលគាំទ្រសេចក្តីបញ្ចប់យកចេញពីអត្ថបទសម្រង់

កំណត់វិធីសាស្ត្រនៃការប្រាប់ចរិតលក្ខណៈ (ឧ. ការជំរុញទឹកចិត្ត អារម្មណ៍)

រកភាពផ្ទុយគ្នានៃគំនិត និងតួអង្គ

ប្រើភស្តុតាងជាក់ស្តែងពីអត្ថបទដើម្បី៖

- ធ្វើសេចក្តីបញ្ចប់ដែលសមហេតុផល
- ធ្វើសេចក្តីសរុប ហើយទាយដោយធម្មតា
- កំណត់ទំនាក់ទំនងហេតុ និងផលធម្មតា
- កំណត់ម្យ៉ាងពិត និងយោបល់ផ្ទាល់ខ្លួន
- សេចក្តីសន្និដ្ឋាន
- ការប្រៀបធៀប

ព្រឹត្តិការណ៍ស្ថានភាពសំខាន់តាមលំដាប់លំដោយ ឬដំណាក់កាលក្នុងដំណើរការតាមលំដាប់នៃកាលប្បវត្តិ

កំណត់ពាក្យអក្សរសាស្ត្រគោល (ឧ. វីរបុរស មនុស្សអាក្រក់។លម។)

សម្គាល់ការប្រើធាតុអក្សរសាស្ត្រ (គំនិតសំខាន់ ព័ត៌មានលម្អិតគាំទ្រ ស្ថានភាព កាលអាកាស ឬប្រធានបទ)

ហត្ថកម្ម និងរចនាសម្ព័ន្ធ (បទដ្ឋាន 4, 5, 6)

ប្រើតម្រុយនៃបរិបទនៅក្នុងអត្ថបទដើម្បីយល់ពីអត្ថន័យរបស់ពាក្យ

ចាត់ថ្នាក់ពាក្យបច្ចេកទេសនៅក្នុងអត្ថបទតាមមុខវិជ្ជា

ប្រើសំណង់ពាក្យដើម្បីបង្កើតអត្ថន័យនៃពាក្យ ឬឃ្លា

ប្រើទំនាក់ទំនងពាក្យ ពាក្យគន្លឹះ និងប្រយោគដើម្បីសម្គាល់ពាក្យភ្ជាប់សេចក្តីតាមបទដ្ឋាន

ភ្ជាប់ន័យបង្កប់ទៅនឹងអត្ថន័យ

កំណត់លក្ខណៈពិសេស ទម្រង់ និងមុខងារនៃអត្ថបទគោល

កំណត់គោលបំណងរបស់អ្នកនិពន្ធនៅក្នុងអត្ថបទ

កំណត់អារម្មណ៍ (បរិយាកាសអារម្មណ៍) និងរចនាបទ (វិធីសាស្ត្រ និងមធ្យោបាយរបស់អ្នកនិពន្ធក្នុងការកំណត់អត្ថន័យ ឧ. ជម្រើសពាក្យ និងសំណង់ប្រយោគ) នៃអត្ថបទ

សម្គាល់ការប្រើឧបករណ៍អក្សរសាស្ត្រ (ឧ. ពាក្យប្រៀបធៀប ពាក្យប្រៀបប្រដូច)

ការយល់ចាប់ចំណេះដឹង និងគំនិត (បទម្ពាន 8 មានតែអត្ថន័យផ្នែកអត្ថបទព័ត៌មាន)

